ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅ**

**របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលហៅកាត់ថាអគ្គលេខាធិការដ្ឋាន **ក.ជ.វ.ប.។**

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា២ ..**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ប.** មានតួនាទីជាសេនាធិការជូន **គ.ជ.ទ.ប.** និងមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់ **គ.ជ.ទ.ប.**
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងហិរញ្ញវត្ថុនិងធនធានរបស់ **គ.ជ.ទ.ប.**
- រៀបចំ រក្សា និងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- ពិនិត្យ តាមដាន វាយតម្លៃ និងជំរុញការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ គោលនយោបាយ ផែនការជាតិ និងការសម្របសម្រួលដើម្បីលើកកម្ពស់ការប្រើប្រាស់ធនធានជាតិសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- រៀបចំនិងបង្កើតកម្មវិធីនិងសេវានានាដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការជាតិសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- លើកសំណើសុំពិនិត្យនិងកែលម្អច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា-ជាតិជូន **គ.ជ.ទ.ប.**
- រៀបចំការប្រជុំ សន្និសីទ សិក្ខាសាលា ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- ជំរុញនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- សម្របសម្រួល លើកកម្ពស់ស្នាដៃនិងការងារអន្តរកម្មជាបណ្តាញក្នុងចំណោមស្ថាប័ន រដ្ឋ ស្ថាប័នឯកជន សង្គមស៊ីវិល អង្គការជាតិ អង្គការអន្តរជាតិ និងអ្នកដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ប្រមូល ចងក្រង កែច្នៃ ប្រើប្រាស់ និងផ្សព្វផ្សាយព័ត៌មានអំពីស្ថានភាពនៃការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការប្រើប្រាស់មូលដ្ឋាននិងបរិក្ខារវិទ្យាសាស្ត្រ និងលទ្ធផលនៃការស្រាវជ្រាវនិងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ប្រមូលនិងផ្តល់ព័ត៌មានពីការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលចាំបាច់

- ធ្វើរបាយការណ៍ជូន **ក.ជ.ទ.ម.** និងស្ថាប័នពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល **ក.ជ.ទ.ម.** ប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋាននៃ **ក.ជ.ទ.ម.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- នាយកដ្ឋានគោលនយោបាយ ផែនការ រដ្ឋបាល ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យា
- នាយកដ្ឋានសហប្រតិបត្តិការនិងការអភិវឌ្ឍធនធានមនុស្ស
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធនិងកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍជាតិ
- នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន **ក.ជ.ទ.ម.** ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ ហើយត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានទាំងអស់នេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

**មាត្រា៥ .-**

អគ្គលេខាធិការដ្ឋាននៃ **ក.ជ.ទ.ម.** មានមន្ត្រីបម្រើការមកពីក្រសួងផែនការ និងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈផ្សេងទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **ក.ជ.ទ.ម.** អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការ និងបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយបំពេញការងាររបស់ខ្លួន។

## ជំពូកទី៤
## តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

**មាត្រា៦ .-**

នាយកដ្ឋានគោលនយោបាយ ផែនការ រដ្ឋបាល ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលនិងរៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធី និងយន្តការផ្សេងៗពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ សម្រាប់ដាក់ជូន **ក.ជ.ទ.ម.** ពិនិត្យនិងសម្រេច/...

- រក្សា ផ្សព្វផ្សាយ និងជំរុញការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- សម្របសម្រួលការងារនិងការកំណត់ធនធានការកសាង និងអនុវត្តផែនការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ធ្វើអង្កេត ជំរឿន និងវិភាគវាយតម្លៃលើកម្លាំងពលកម្ម(សមត្ថភាពចំណេះដឹង) និងប្រភពធនធានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាសម្រាប់រៀបចំធ្វើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- បំពេញការងាររដ្ឋបាលនិងធានានិរន្តរភាពការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប.**
- រៀបចំនិងចាត់ចែងកិច្ចប្រជុំរបស់ **គ.ជ.វ.ប.** និងធ្វើរបាយការណ៍នៃកិច្ចប្រជុំនេះ
- ធ្វើរបាយការណ៍បូកសរុបអំពីសកម្មភាពនិងលទ្ធផលការងារនៃអគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប.**
- គ្រប់គ្រងចំណូល ចំណាយ និងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.វ.ប.**
- រៀបចំបង្កើត ប្រើប្រាស់ និងគ្រប់គ្រងមូលនិធិសម្រាប់អភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកក្នុងអគ្គលេខាធិការដ្ឋាន
- សម្របសម្រួល លើកទឹកចិត្តនិងលើកកម្ពស់ស្នាដៃនិងការងារអន្តរកម្មជាបណ្តាញក្នុងចំណោមស្ថាប័នរដ្ឋ ស្ថាប័នឯកជន សង្គមស៊ីវិល អង្គការជាតិ អង្គការអន្តរជាតិ និងអ្នកដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ផ្គត់ផ្គង់និងរៀបចំសម្ភារៈ បរិក្ខារ និងគ្រប់គ្រងបញ្ជីសារពើភណ្ឌចលនទ្រព្យនិងអចលនទ្រព្យរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋានសម្រាប់រយៈពេលខ្លី មធ្យម និងវែង
- សម្របសម្រួល ចងក្រង និងបូកសរុបការងារពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដាក់ជូន **គ.ជ.វ.ប.** ដើម្បីពិនិត្យនិងសម្រេច
- បង្កើតនិងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គាំទ្រទំនាក់ទំនងនិងការងាររបស់អគ្គលេខាធិការដ្ឋាន
- បង្កើត គ្រប់គ្រង និងសម្រួលការប្រើប្រាស់មូលទិន្នន័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងប្រព័ន្ធកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍជាតិ
- ប្រមូល ចងក្រង រក្សាទុក និងផ្សព្វផ្សាយព័ត៌មានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- ប្រមូល កែច្នៃ វិភាគ និងផ្សព្វផ្សាយលទ្ធផលជំរឿន អង្កេតដែលទាក់ទងនឹងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- បង្កើតនិងកែលម្អគេហទំព័រស្តីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប.** ប្រគល់ជូន។

**មាត្រា៧.-**

នាយកដ្ឋានសហប្រតិបត្តិការនិងការអភិវឌ្ឍធនធានមនុស្ស មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- បង្កើតបណ្តាញសហប្រតិបត្តិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិនិងអន្តរជាតិ
- ប្រមូល និងផ្តល់ព័ត៌មានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា គោលនយោបាយវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃបណ្តាប្រទេសជឿនលឿន ជូនអង្គភាពរដ្ឋ និងឯកជនដែលពាក់ព័ន្ធ
- សម្របសម្រួលធនធាននិងតម្រូវការសម្រាប់អភិវឌ្ឍកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- រៀបចំ ដំណើរការ និងគ្រប់គ្រងកម្មវិធីស្រាវជ្រាវរួមជាមួយអន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងសម្របសម្រួលតម្រូវការប្រើប្រាស់អ្នកវិទ្យាសាស្ត្រនិងវិស្វករពីបណ្តាប្រទេសជឿនលឿន
- ធ្វើការសិក្សា ស្រាវជ្រាវ និងសម្របសម្រួលតម្រូវការ និងការផ្គត់ផ្គង់ធនធានមនុស្សផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ធ្វើផែនការសម្រាប់ការអភិវឌ្ឍធនធានមនុស្ស ការកសាងសមត្ថភាព និងរៀបចំកម្មវិធីបណ្តុះបណ្តាលទាក់ទងនឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងនិងក្រៅប្រទេស
- សម្របសម្រួលជាមួយបណ្តាប្រទេសជឿនលឿនលើវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងការស្នើសុំការបណ្តុះបណ្តាលនិងចែករំលែកបទពិសោធ
- ឃោសនានិងផ្សព្វផ្សាយជាសាធារណៈពីសារៈសំខាន់នៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានិងជួយជំរុញការចូលរួម
- សម្របសម្រួល គ្រប់គ្រង និងចាត់ចែងធនធានមនុស្សសម្រាប់វិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប.** ប្រគល់ជូន។

**មាត្រា៨ .-**

នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធនិងកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍជាតិ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ និងសម្របសម្រួលតម្រូវការ និងការផ្គត់ផ្គង់មជ្ឈមណ្ឌលនិងបរិក្ខារស្រាវជ្រាវនិងអភិវឌ្ឍជាតិ
- ប្រមូល ចងក្រង ផ្សព្វផ្សាយ ព័ត៌មានមជ្ឈមណ្ឌល និងបរិក្ខារស្រាវជ្រាវនិងអភិវឌ្ឍ និងសម្រួលការប្រើប្រាស់
- សម្របសម្រួល វាយតម្លៃ និងបង្កើតកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍជាតិ
- ប្រមូលទិន្នន័យកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍពីក្រសួងស្ថាប័នពាក់ព័ន្ធ និងបណ្តាផ្នែកអនុវត្តកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍដើម្បីវិភាគ វាយតម្លៃ កំណត់ទិសដៅ និងផ្សព្វផ្សាយ
- សម្របសម្រួលនិងជួយជំរុញពាណិជ្ជូបនីយកម្មលទ្ធផលនៃការស្រាវជ្រាវនិងការអភិវឌ្ឍ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.ទ.ប.** ប្រគល់ជូន។

**មាត្រា៩ .-**

នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងកំណត់សូចនាករដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- រៀបចំរបាយការណ៍នៃការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ និងលើកជាអនុសាសន៍ជូន **គ.ជ.ទ.ប.** ដើម្បីពិនិត្យនិងសម្រេច
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើបុគ្គលនិងស្ថាប័នដែលមានស្នាដៃក្នុងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងលើកជាសំណើជូន **គ.ជ.ទ.ប.** ដើម្បីពិនិត្យនិងសម្រេចការលើកទឹកចិត្ត
- ផ្សព្វផ្សាយលទ្ធផលនៃការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃដល់ក្រសួង ស្ថាប័ន និងបុគ្គលដែលពាក់ព័ន្ធ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន**គ.ជ.ទ.ប.**ប្រគល់ជូន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ**

**នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៥**

**ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ**
**របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា**

**អង្គការលេខនៃអគ្គលេខាធិការដ្ឋាន ក.ជ.វ.ប.**

